# សាររបស់ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឱកាសរំលឹកខួប ASEM DAY

## ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

1. ថ្ងៃនេះ ថ្ងៃទី០១ ខែមីនា គឺជាថ្ងៃរំលឹកខួបប្រចាំឆ្នាំលើកទី២ នៃទិវា ASEM DAY ដែលត្រូវបានកំណត់ឡើងដោយមេដឹកនាំនៃទ្វីបអាស៊ី និងអឺរ៉ុប ក្នុងកិច្ចប្រជុំកំពូលលើកទី១១ កាលពីខែកក្កដា ឆ្នាំ២០១៦ នៅក្នុងទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលី។ ក្នុងឱកាសដ៏វិសេសវិសាលនេះ តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមសម្តែងនូវគារវកិច្ចដ៏កក់ក្តៅ និងសូមប្រសិទ្ធពរជូនពរប្រជាជនកម្ពុជា និងប្រជាជនអាស៊ី-អឺរ៉ុបទាំងអស់ ឱ្យទទួលបាននូវសេចក្តីសុខ និងវិបុលភាពគ្រប់ៗគ្នា។

2. ចាប់តាំងពីកិច្ចប្រជុំកំពូលលើកដំបូងក្នុងខែមីនា ឆ្នាំ១៩៩៦ នៅទីក្រុងបាងកក ដែលមានរដ្ឋដៃគូជាសមាជិកចំនួន ២៦ ចូលរួមមកកិច្ចប្រជុំអាស៊ី-អឺរ៉ុប (Asia-Europe Meeting-ASEM) នេះ បានផ្លាស់ប្តូរយ៉ាងខ្លាំង និងបានបង្ហាញឱ្យឃើញនូវតម្លៃរបស់ខ្លួនតាមរយៈការពង្រីកសមាជិកដល់ ទៅ ៥៣ ប្រទេស មកពីទ្វីបអាស៊ី និងអឺរ៉ុប ដែលបានធ្វើឱ្យ ASEM ក្លាយជាវេទិកាអន្តរតំបន់ដ៏ធំជាងគេមួយ នៅក្នុងពិភពលោក និងតំណាងឱ្យផលិតផលក្នុងស្រុកសរុប (GDP) ពិភពលោកប្រមាណ ៥០ភាគរយ ប្រជាជនពិភពលោក ជិត ៦០ភាគរយ និងពាណិជ្ជកម្មពិភពលោក ៦០ភាគរយ។

3. ជាង ២ ទសវត្សរ៍កន្លងមកនេះ ASEM បានដើរតួនាទីគន្លឹះជាវេទិកាដ៏សំខាន់តែមួយគត់សម្រាប់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងទ្វីបអាស៊ី និងអឺរ៉ុប ដែលមានគោលបំណងសំខាន់ ដើម្បីពង្រឹងភាពជាដៃគូ ជំរុញសន្តិភាព និងសន្តិសុខ ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពរវាងតំបន់ទាំងពីរ និងសកលលោកទាំងមូល។

4. គុណតម្លៃ និងសារៈសំខាន់ ដែលកំពុងបន្តមានរបស់ ASEM នៅក្នុងកិច្ចការនយោបាយ ការទូត និងទំនាក់ទំនងអន្តរតំបន់ នាពេលបច្ចុប្បន្ននេះ គឺមិនអាចប្រកែកបានឡើយ និងបានវិវត្តស្របទៅនឹងការផ្លាស់ប្តូរបរិយាកាសសកល ការសម្របខ្លួនទៅនឹងពិភពលោកពហុប៉ូល ដែលកំពុងតែងើបឡើង ការពង្រីកខ្លួនរបស់សហភាពអឺរ៉ុប និងតំបន់អាស៊ីមួយ ដែលកាន់តែមានការពឹងអាស្រ័យគ្នាទៅវិញទៅមក។ ដំណើរការនេះ កាន់តែមានការវិវឌ្ឍបន្ថែមទៀត ដោយបានឆ្លុះបញ្ចាំងនូវបញ្ហាប្រឈមសកលថ្មីៗ ដែលតម្រូវឱ្យតំបន់អាស៊ី និងអឺរ៉ុបដោះស្រាយរួមគ្នា និងឈានឆ្ពោះទៅប្រែក្លាយដំណើរការនៃកិច្ចសន្ទនាក្រៅផ្លូវការរបស់ ASEM ឱ្យទទួលបានលទ្ធផលជាក់ស្តែង និងគោលនយោបាយរួម។ បច្ចុប្បន្ននេះ ដៃគូ ASEM បានអនុវត្តសកម្មភាពនានា ដែលរួមបញ្ចូលកិច្ចសហប្រតិបត្តិការលើវិស័យទាំង ២០ នៃកិច្ចសហប្រតិបត្តិការជាក់ស្តែង ដោយផ្តោតសំខាន់ទៅលើសសរស្តម្ភទាំង ៣ របស់ ASEM គឺនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។

5. ខណៈដែល ASEM ឈានចូលទសវត្សរ៍ទី៣ របស់ខ្លួន «សេចក្តីប្រកាសទីក្រុងអ៊ូឡង់បាទ័រ» ដែលត្រូវបានអនុម័តកាលពីកិច្ចប្រជុំកំពូល ASEM លើកទី១១ បានបញ្ជាក់យ៉ាងច្បាស់ថា ASEM ជា

វេទិកាដ៏សំខាន់មួយក្នុងការតម្រែតម្រង់របៀបរបបពិភពលោក ក្នុងសតវត្សរ៍ទី២១នេះ តាមរយៈការចូលរួមចំណែកដល់សន្តិភាព សន្តិសុខ ស្ថិរភាព ការងើបឡើងនៃសេដ្ឋកិច្ច ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ពិភពលោក និងនៅក្នុងតំបន់។ ថ្នាក់ដឹកនាំរបស់ ASEM បានសំដែងនូវការប្តេជ្ញាចិត្តក្នុងការដឹកនាំ ASEM ឆ្ពោះទៅរកភាពជោគជ័យនៅក្នុងទសវត្សរ៍ទី៣របស់ខ្លួន តាមរយៈការពង្រឹងភាពជាដៃគូ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការ ដើម្បីទទួលបានផលប្រយោជន៍ជាក់ស្តែង ជំរុញការតភ្ជាប់ឱ្យបានគ្រប់ជ្រុង និងជំរុញឱ្យមានទម្រង់ក្រៅផ្លូវការ ការបង្កើតបណ្តាញទំនាក់ទំនង និងភាពបត់បែនថែមទៀត។

6. នៅក្នុងបរិបទនៃការផ្លាស់ប្តូរយ៉ាងលឿន និងពិភពលោកដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ននេះ យើងចាំបាច់ត្រូវការ ASEM មួយប្រកបដោយបរិយាប័ន្ន និងមានការចូលរួមបន្ថែមទៀត ជាពិសេសពីសង្គមស៊ីវិល យុវជន អ្នកសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមធុរៈកិច្ច។ ការប្រាស្រ័យទាក់ទងគ្នា និងទំនាក់ទំនងកាន់តែជិតស្និទ្ធបន្ថែមទៀត គឺចាំបាច់សម្រាប់ ASEM ដើម្បីពង្រឹងចំណេះដឹងពីបញ្ហាប្រឈមសកលដ៏ស្មុគស្មាញ ដែលរាប់ចាប់តាំងពីបញ្ហាភេរវកម្ម អន្តោប្រវេសន៍ ភាពក្រីក្រ រហូតដល់ការប្រែប្រួលអាកាសធាតុ ដែលបញ្ហាទាំងអស់នេះ ទាមទារឱ្យសមាជិក ASEM ត្រូវដោះស្រាយរួមគ្នា បើទោះបីជាទីតាំងភូមិសាស្ត្រនៅឆ្ងាយពីគ្នាក៏ដោយ។

7. ជាមួយគ្នានេះ កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបលើកទី១៣ ដែលបានធ្វើឡើងនៅថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងណៃពិដោរ ប្រទេសមីយ៉ាន់ម៉ា បានអះអាងជាថ្មីអំពីតម្លៃជាសារវន្តនៃភាពជាដៃគូស្មើភាព ការគោរពគ្នា និងការផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក។ អង្គប្រជុំបានសង្កត់ធ្ងន់លើតម្រូវការក្នុងការចូលរួមឲ្យកាន់តែជិតស្និទ្ធ សំដៅឆ្ពោះទៅរកភាពជាដៃគូកាន់តែក្លៀវក្លា និងរឹងមាំ ក្នុងដំណើរការដោះស្រាយបញ្ហាសកល និងការបង្កើតឱ្យមានបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍឲ្យកាន់តែមានតុល្យភាព ចីរភាព និងខ្លាំងក្លាឡើងថែមទៀត។ អង្គប្រជុំបានអនុម័តផងដែរ លើការងាររបស់ក្រុមការងារស្វែងរកមាគ៌ារបស់ ASEM ស្តីពីការតភ្ជាប់ (ASEM Pathfinder Group on Connectivity-APGC) ដែលរួមមាននិយមន័យនៃការតភ្ជាប់របស់ ASEM ដែលក្តោបលើបរិធានរឹង និងទន់ រួមមានការតភ្ជាប់វប្បធម៌-សង្គម និងការតភ្ជាប់រូបវន្ត ដែលជាមធ្យោបាយគាំទ្រយ៉ាងសំខាន់ ដើម្បីជម្រុញចំណងសេដ្ឋកិច្ច សន្តិសុខ-នយោបាយ និងវប្បធម៌-សង្គម រវាងអាស៊ី និងអឺរ៉ុប។

8. សម្រាប់ប្រទេសកម្ពុជា យើងចាត់ទុកកិច្ចប្រជុំអាស៊ី-អឺរ៉ុប ជាវេទិកាក្រៅផ្លូវការដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការតំបន់និងតំបន់។ កិច្ចប្រជុំអាស៊ី-អឺរ៉ុប បានផ្តល់ផលប្រយោជន៍ជាច្រើនដល់កម្ពុជា។ **<u>ទី១</u>** កិច្ចប្រជុំអាស៊ី-អឺរ៉ុប បានផ្តល់ឱ្យកម្ពុជានូវវេទិកាដ៏ប្រសើរ ដើម្បីលើកកម្ពស់មុខមាត់កម្ពុជាក្នុងឆាកអន្តរជាតិ។ **<u>ទី២</u>** កិច្ចប្រជុំនេះបានផ្តល់ឱកាសក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយនឹងសមាជិកដទៃទៀតតាមរយៈកិច្ចប្រជុំកម្រិតខ្ពស់របស់ ASEM និងជំរុញវិស័យជាក់លាក់នៃកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា រួមមានការផ្លាស់ប្តូរពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ជាដើម។ **<u>ទី៣</u>** ASEM បានរួមចំណែកលើកស្ទួយការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាទាំងវិស័យឯកជន និងសាធារណៈ។ **<u>ទី៤</u>** ការតភ្ជាប់របស់ ASEM គឺជាការតភ្ជាប់ដ៏រស់រវើកបំផុតមួយ

សម្រាប់កម្ពុជាក្នុងការផ្លាស់ប្តូរប្រជាជន និងប្រជាជន នៅក្នុងតំបន់អាស៊ី-អឺរ៉ុប ដែលមានការតភ្ជាប់គ្នាកាន់តែខ្លាំងឡើងៗ។

9. ចាប់តាំងពីក្លាយជាសមាជិកផ្លូវការរបស់កិច្ចប្រជុំអាស៊ី-អឺរ៉ុប នាកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី៥ នៅឆ្នាំ២០០៤ ក្នុងប្រទេសវៀតណាម កម្ពុជាបានចូលរួមសកម្មភាព និងព្រឹត្តិការណ៍នានាយ៉ាងសកម្ម ក្រោមក្របខ័ណ្ឌរបស់កិច្ចប្រជុំអាស៊ី-អឺរ៉ុប។ ជាក់ស្តែង ក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ កម្ពុជាបានរៀបចំបាឋកថាសាធារណៈ ដោយមានការចូលរួមពីសិស្សនិស្សិតប្រមាណជា៦០០ នាក់ ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប។ ចាប់តាំងពីឆ្នាំ២០០៥មក កម្ពុជាបានចូលរួមបង់វិភាគទានស្ម័គ្រចិត្តចំនួនមួយម៉ឺនដុល្លារអាមេរិកជារៀងរាល់ឆ្នាំ ដល់មូលនិធិអាស៊ី-អឺរ៉ុប (Asia-Europe Foundation-ASEF) ដើម្បីគាំទ្រសកម្មភាពនានារបស់ ASEF ដែលជួយបំពេញនូវដំណើរការរបស់កិច្ចប្រជុំអាស៊ី-អឺរ៉ុប ដែលដឹកនាំដោយរដ្ឋាភិបាល ជាពិសេសលើវិស័យ វប្បធម៌ អប់រំ និងយុវជន ព្រមទាំងចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍នានា រៀបចំដោយ ASEF។

10. ដើម្បីទទួលបានប្រយោជន៍បន្ថែមទៀត និងជួយលើកកម្ពស់ការយល់ដឹងជាសាធារណៈនិងបញ្ជ្រាបការយល់ដឹងអំពីដំណើរការរបស់ ASEM រដ្ឋាភិបាលតែឯងមិនអាចធ្វើការលើរឿងនេះបានជោគជ័យនោះឡើយ។ ដូច្នេះ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធដូចជាស្ថាប័នផ្សព្វផ្សាយ សង្គមស៊ីវិល វិស័យឯកជន និងជាពិសេស យុវជន ដែលជាអ្នកជំនាន់ក្រោយចូលរួមឲ្យបានសកម្មនៅក្នុងដំណើរការរបស់ ASEM ដើម្បីលើកកម្ពស់ និងនាំយកមុខមាត់របស់ ASEM ឱ្យឈានឡើងមួយកម្រិតទៀត ជាពិសេសក្នុងន័យនៃការតភ្ជាប់ ឬទំនាក់ទំនងមិត្តភាពទាំងក្នុងទ្វីបអាស៊ី និងអឺរ៉ុប ក៏ដូចជាលើពិភពលោកទាំងមូលផងដែរ។

11. ដោយរំពឹងទុកចំពោះកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨-១៩ ខែតុលា ឆ្នាំ២០១៨ខាងមុខ នៅទីក្រុងប្រ៊ុចសែល ក្រោមមូលបទគន្លឹះ៖ «អឺរ៉ុប និងអាស៊ី៖ ដៃគូសកលសម្រាប់ការប្រឈមសកល» **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នឹងដឹកនាំប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ទៅចូលរួមកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។ ការអញ្ជើញចូលរួមរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងកិច្ចប្រជុំកំពូលនេះ នឹងបង្ហាញយ៉ាងច្បាស់ពីការបន្តប្តេជ្ញាចូលរួមយ៉ាងសកម្មរបស់កម្ពុជាក្នុងដំណើរការរបស់ ASEM ដើម្បីដោះស្រាយបញ្ហាប្រឈមសកលនាពេលបច្ចុប្បន្ន និងស្វែករកឱកាសដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការជាមួយដៃគូ ASEM ទាំងអស់។

12. ជាទីបញ្ចប់ ខ្ញុំសូមអះអាងជាថ្មីនូវការប្តេជ្ញាចិត្តផ្ទាល់ចំពោះការផ្តល់តម្លៃដល់ ASEM និងសូមឱ្យទិវា ASEM ក្នុងឆ្នាំនេះ ក្លាយជាព្រឹត្តិការណ៍ជាក់ស្តែងមួយក្នុងដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកវិបុលភាពរួមក្នុងទសវត្សរ៍ទី៣នេះ ព្រមទាំងទសវត្សរ៍ក្រោយៗទៀត៕

----------------